**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

Ministry of Industry & Handicraft

លេខ: ១២៣ MIH / 2015

# ប្រកាស

## ស្តីពី

## ការធ្វើប្រតិភូកម្មមុខងារត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និងទំនិញវេចខ្ចប់ ជូនមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី ខេត្ត

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រ

-បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញប្រកាសលេខ ៤១៥ MIH/2014 ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីបទប្បញ្ញត្តិបច្ចេកទេសត្រួតពិនិត្យផ្ទៀងផ្ទាត់បរិមាណ និងស្លាកសញ្ញាទំនិញផលិត និងទំនិញវេចខ្ចប់

-បានឃើញប្រកាសលេខ ៤១២ MIH/2014 ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីសញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ

-បានឃើញប្រកាសលេខ ៤១៣ MIH/2014 ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីបទប្បញ្ញត្តិបច្ចេកទេសត្រួតពិនិត្យផ្ទៀងផ្ទាត់ជញ្ជីងមិនស្វ័យប្រវត្តិ

-យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## <u>សម្រេច</u>

**ប្រការ១_**

ត្រូវបានធ្វើប្រតិភូកម្មមុខងារត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និងទំនិញវេចខ្ចប់ ជូនមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី ខេត្ត ដូចខាងក្រោម៖

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ៤២៨ ២៦៣
អ៊ីម៉ែល: mih.smcabinet@gmail.com

4.

Scanned by CamScanner

ក- ការត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ៖

- ជញ្ជីងមិនស្វ័យប្រវត្តិ ដែលមានសមត្ថភាពត្រឹម១០០០(មួយពាន់)គីឡូក្រាមចុះក្រោម
- ជញ្ជីងសម្រាប់ថ្លឹងវត្ថុមានតម្លៃ ដូចជា មាស ប្រាក់ ប្លាទីន ត្បូងពេជ្រ...
- ដៃបាញ់ប្រេងនៅតាមស្ថានីយ៍ ដេប៉ូលក់ ចែកចាយប្រេងឥន្ធនៈ និងឧស្ម័ន
- ឧបករណ៍វាស់ប្រេងឥន្ធនៈ ដែលប្រើកែវក្រិតវ៉ៃ។

ខ- ការត្រួតពិនិត្យផ្ទៀងផ្ទាត់ទំនិញផលិត និងទំនិញវេចខ្ចប់ ដែលបានផលិត និងចរាចរនៅលើទីផ្សារក្នុងភូមិសាស្ត្រ រាជធានី ខេត្ត។

**ប្រការ២_**

មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត មានភារកិច្ចអនុវត្តឱ្យបានត្រឹមត្រូវតាមនីតិវិធី ព្រមទាំងលក្ខខណ្ឌ និងបទដ្ឋានបច្ចេកទេស ដែលបានកំណត់ដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ហើយត្រូវមានកាតព្វកិច្ចធ្វើរបាយការណ៍ជូនមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិតាមការតម្រូវ។

**ប្រការ៣_**

មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិមានសិទ្ធិចុះត្រួតពិនិត្យ និងធ្វើអធិការកិច្ចលើការបំពេញមុខងារដែលបានធ្វើប្រតិភូកម្មជូនមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ដូចមានចែងក្នុងប្រការ១ ខាងលើ។

**ប្រការ៤_**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥_**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល គ្រប់អង្គភាពក្រោមឱវាទក្រសួង ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០១៥

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល៖**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលារាជធានី ខេត្ត
- ដូចប្រការ៥

រាជកិច្ច

ឯកសារ កាលប្បវត្តិ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
National Metrology Center
លេខៈ ៣១៤/......NMC
/២០១៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

## ផែនការចុះអង្កេត និងពង្រឹងការអនុវត្ត ត្រួតពិនិត្យផ្ទៀងផ្ទាត់ ការងារមាត្រាសាស្ត្រ ក្រោយពីប្រកាសប្រតិភូកម្មមុខងារ លេខៈ123 MIH/2015 ជូនមន្ទីរឧស្សាហកម្ម និង សិប្បកម្ម រាជធានី-ខេត្ត ចាប់ពីចុងឆមាសទី I និង ឆមាសទី II ឆ្នាំ ២០១៦

| ល.រ. | រាជធានី-ខេត្ត | កាលបរិច្ឆេទ | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | |
| ០១ | កំពង់ឆ្នាំង | 2-6 | | | | | | ការិយាល័យត្រួតពិនិត្យ |
| ០២ | ពោធិ៍សាត់ | 2-6 | | | | | | ផ្ទៀងផ្ទាត់ឧបករណ៍មា |
| ០៣ | បាត់ដំបង | 2-6 | | | | | | ត្រាសាស្ត្រ |
| ០៤ | ប៉ៃលិន | 9-12 | | | | | | -កូនទម្ងន់ |
| ០៥ | បន្ទាយមានជ័យ | 9-12 | | | | | | -ជញ្ជីងឌីជីថល |
| ០៦ | កំពង់ធំ | 16-19 | | | | | | -Vessel ៥លីត្រ |
| ០៧ | សៀមរាប | 16-19 | | | | | | និង១០លីត្រ |
| ០៨ | ព្រះវិហារ | 23-27 | | | | | | ការិយាល័យត្រួតពិនិត្យ |
| ០៩ | ឧត្តរមានជ័យ | 23-27 | | | | | | ផ្ទៀងផ្ទាត់ទំនិញផលិត |
| ១០ | ព្រៃវែង | | 6-10 | | | | | និងទំនិញវេចខ្ចប់ |
| ១១ | ស្វាយរៀង | | 6-10 | | | | | -កែវក្រិត |
| ១២ | តាកែវ | | 13-17 | | | | | -ទែម៉ូម៉ែត្រ |
| ១៣ | កំពត | | 13-17 | | | | | -ជញ្ជីង |
| ១៤ | កែប | | 13-17 | | | | | -មេក្រូម៉ែត្រ |
| ១៥ | កំពង់ស្ពឺ | | 20-24 | | | | | -ពីពែត្រ |
| ១៦ | ព្រះសីហនុ | | 20-24 | | | | | -ម៉ែត្រគាប់ |
| ១៧ | កោះកុង | | 20-24 | | | | | -ម៉ែត្រ ឬ បន្ទាត់ |
| ១៨ | កំពង់ចាម | | 27-30 | | | | | |
| ១៩ | ត្បូងឃ្មុំ | | | 4-7 | | | | |
| ២០ | ក្រចេះ | | | 11-15 | | | | |
| ២១ | មណ្ឌលគិរី | | | 11-15 | | | | |
| ២២ | រតនៈគិរី | | | 18-22 | | | | |
| ២៣ | ស្ទឹងត្រែង | | | 18-22 | | | | |

លេខ ២០៥ ផ្លូវជាតិលេខ ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ
រាជធានីភ្នំពេញ. ទូរស័ព្ទ/ទូរសារ៖ (៨៥៥)២៣ ២៣ ០២ ១១, ២៣ ៤២ ៦៦ ០៣
No. 205 National Road 5, Sangkat Km 6, Khan Russey Keo,
Phnom Penh, Cambodia.Tel / Fax: (855)23 23 02 11,23 42 66 03

Scanned by CamScanner

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២៤ | ភ្នំពេញ | | | | 25-29 | | | |
| ២៥ | កណ្តាល | | | | 25-29 | | | |

រាជធានីភ្នំពេញ, ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ ២០១៦.

**ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ**

**ពៅ ទរលក្សណ៍**

**<u>ចម្លងជូន៖</u>**

- ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
- រដ្ឋលេខាធិការទទួលបន្ទុក
- អនុរដ្ឋលេខាធិការទទួលបន្ទុក
- គ្រប់នាយកដ្ឋានចំណុះម.ម.ជ.
- មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ


លេខ ២០៥ ផ្លូវជាតិលេខ ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ
រាជធានីភ្នំពេញ. ទូរស័ព្ទ/ទូរសារ៖ (៨៥៥)២៣ ២៣ ០២ ១១, ២៣ ៤២ ៦៦ ០៣

No. 205 National Road 5, Sangkat Km 6, Khan Russey Keo,
Phnom Penh, Cambodia. Tel / Fax: (855)23 23 02 11,23 42 66 03


Scanned by CamScanner